សន្លឹកព័ត៌មានគន្លឹះអំពីសារធាតុសំណ #3

# ប្រភពសារធាតុសំណ

ខែមករា ឆ្នាំ 2023



**មូលហេតុសាមញ្ញបំផុត ចំពោះការពុលសារធាតុសំណក្នុងវ័យកុមារ នៅរដ្ឋមេន គឺកើតចេញពីធូលីរបស់ថ្នាំលាបផ្ទះដែលមានលាយសារធាតុសំណ ។**

ក្នុងមួយឆ្នាំៗ កុមាររបស់រដ្ឋមេន ចំនួនច្រើនជាង 300 នាក់ ទទួលរងការពុលសារធាតុសំណ ។ ធូលីសំណដែលធ្លាក់នៅលើកម្រាល និងតាមរបស់ផ្សេងទៀត ដែលកុមារតែងយកដៃទៅចាប់ និងលេងប្រដាប់លេង ។ កុមារ ជាពិសេស ក្មេងដែលមានអាយុក្រោម 3 ឆ្នាំ តែងដាក់ដៃ និងប្រដាប់លេងចូលក្នុងមាត់ ។ ស្ថានភាពនេះ ធ្វើឲ្យធូលីសំណ អាចចូលក្នុងរាងកាយ និងធ្វើឲ្យខូចរាងកាយរបស់ពួកគេ ដែលកំពុងលូតលាស់ ។

## ធូលីសំណ ពីថ្នាំលាបផ្ទះដែលមានលាយសារធាតុសំណ

នៅពេលដែលថ្នាំលាបផ្ទះដែលមានលាយសារធាតុសំណ ចាស់ទៅ ហើយប្រេះចេញពីគ្នា ធូលីសំណអាចកកនៅតាមបន្ទះទ្របង្អួច និងកម្រាលផ្ទះ របស់អ្នក ។ ធូលីសំណនេះ អាចនៅក្នុងផ្ទះរបស់អ្នក ក្នុងរយៈពេលយូរ ។ បរិវេណផ្ទះដែលថ្នាំលាប រងការកកិត ដូចជាក្របទ្វារ ក្របបង្អួច ឬសូម្បីតែកម្រាលដែលអ្នកដើរជាន់ អាចបង្ករឲ្យមានធូលីមានលាយសារធាតុសំណ ។

ធូលីសំណ ក៏អាចចេញពីការជួសជុល និងការកែលំអផ្ទះ ផងដែរ ។ បើអ្នកខាត់ កោស ឬដុសបរិវេណដែលលាបថ្នាំមានលាយសារធាតុសំណ វាអាចបង្ករឲ្យមានធូលីសំណកើតឡើង ។ បើអ្នកធ្វើការក្នុងផ្ទះនរណាម្នាក់ ដែលលាបដោយថ្នាំលាបមានលាយសារធាតុសំណ វាអាចធ្វើឲ្យអ្នកនាំយកធូលីសំណទាំងនោះចូលក្នុងឡាន និងផ្ទះរបស់អ្នក ។ រាល់ពេលដែលអ្នកនាំយកធូលីសំណចូលក្នុងផ្ទះ គឺវាធ្វើឲ្យធូលីសំណកាន់តែកើនឡើងនៅក្នុងផ្ទះរបស់អ្នក ។

## សំណពីប្រភពផ្សេងទៀត

ថ្នាំលាបផ្ទះមានលាយសារធាតុសំណ គឺជាប្រភពសាមញ្ញបំផុតដែលបណ្តាលឲ្យមានការពុលសារធាតុសំណ ។ ជួនកាល ប្រភពធូលីសំណផ្សេងទៀត ក៏សំខាន់ណាស់ដែរក្នុងការបង្ករឲ្យមានការពុលសារធាតុសំណ ។

**ដី ជាពិសេស ដីដែលនៅក្បែរអគារចាស់ៗ** ។ បើគេប្រើថ្នាំលាបដែលមានលាយសារធាតុសំណ លើជញ្ជាំងផ្នែកខាងក្រៅ កំទេចថ្នាំ ឬធូលីសំណ អាចធ្លាក់ចូលក្នុងដីត្រង់បរិវេណជុំវិញអគារនោះ ។ ចំណុចនេះ ក៏វាអាចបណ្តាលឲ្យកើតមានការពុលសារធាតុសំណដែរ ដោយសារថា ដៃរបស់កុមារខ្លះអាចប្រឡាក់ដីនេះ រួចហើយដីប្រឡាក់ដៃនេះ អាចចូលក្នុងមាត់របស់កុមារនោះ ។ ឲ្យកូនរបស់អ្នកលេងលើស្មៅ ឬលេង ក្នុងប្រអប់ខ្សាច់សម្រាប់ក្មេងលេង ហើយមិនត្រូវឲ្យពួកគេ លេងលើដីផ្ទាល់ ឬគំនរដីឡើយ ។ សូមប្រើកម្រាលជូតជើង ដើម្បីការពារកុំឲ្យធូលីសំណចូលក្នុងផ្ទះរបស់អ្នក ។ សូមអានព័ត៌មានក្នុងសន្លឹកព័ត៌មានគន្លឹះលេខ 4 **ការធ្វើតេស្តផ្ទះរបស់ខ្ញុំរកមើលសារធាតុសំណ** ដើម្បីសិក្សាអំពីរបៀបធ្វើតេស្តដីរកមើលសារធាតុសំណ ។

**កិច្ចការកំសាន្ត** ។ កិច្ចការកំសាន្តខ្លះ អាចធ្វើឲ្យអ្នកប្រឈមជាមួយនឹងសារធាតុសំណ ។ មានដូចជា ៖ ឆ្លាក់ក្បាច់លើកែវ, ចាក់ដុំសំណសម្រាប់ទាញពន្លិចផ្លែសន្ទូច, ធ្វើគ្រាប់កាំភ្លើងសំណដោយខ្លួនឯង (សម្រាប់ច្រកក្នុងកាណុងកាំភ្លើង) ឬ ការដុសខាត់តុទូរ ។ បើកិច្ចការកំសាន្តរបស់អ្នក ធ្វើឲ្យអ្នកប្រឈមជាមួយនឹងសារធាតុសំណ សូមស្លៀកសម្លៀកបំពាក់ពិសេសសម្រាប់ធ្វើកិច្ចការកំសាន្ត ហើយបោកគក់វាដាច់ដោយឡែកពីខោអាវទូទៅ លាងសំអាតដៃដោយសាប៊ូ ហើយមិនត្រូវឲ្យកូនៗរបស់អ្នក ពាក់ព័ន្ធជាមួយនឹងកិច្ចការនេះឡើយ ។

**វត្ថុបុរាណ ឬគ្រឿងសង្ហារិម និងប្រដាប់លេង លាបថ្នាំចាស់ៗ** ។ ថ្នាំលាបណាដែលបានយកមកប្រើ មុនឆ្នាំ 1978 អាចមានលាយសារធាតុសំណ ។ ថ្នាំលាបដែលបានផលិតមុនឆ្នាំ 1950 មានលាយសារធាតុសំណច្រើនជាងគេ ។ ត្រូវប្រាកដថា វត្ថុបុរាណ ឬរបស់លេងលាបថ្នាំចាស់ ស្ថិតក្នុងស្ថានភាពល្អ (ថ្នាំមិនប្រេះ ឬរបក) ហើយត្រូវរក្សាទុកឲ្យផុតដៃក្មេង ។

**កទឹ** ។ សារធាតុសំណចេញពីទង់ដែង, សំណចេញពីប្រដាប់សម្រាប់ផ្សារ ឬទុយ៉ូសំណ អាចរលាយក្នុងទឹក ។ ផឹកទឹកពីក្បាលរ៉ូប៊ីណេទឹកត្រជាក់ ហើយបើកទឹកបង្ហូរចោលមួយសន្ទុះ មុនបើកដាក់កែវ ។ បើអ្នកប្រើអណ្តូងខ្លួនឯង សូមធ្វើតេស្តទឹកអណ្តូងរបស់អ្នក ។ សូមអានព័ត៌មានក្នុងទំព័រ wellwater.maine.gov ដើម្បីសិក្សាពីរបៀបធ្វើតេស្ត ។

**របស់លេង និងផលិតផលផ្សេងទៀត** ។ វាជាករណីកម្រ ដែលកុមារពុលសារធាតុសំណ ដែលមានជាប់នៅតាមប្រដាប់លេង ។ អ្នកអាចបើកមើលព័ត៌មានក្នុងទំព័រ cpsc.gov ដើម្បីសិក្សាអំពីការប្រមូលរបស់លេង និងផលិតផលផ្សេងទៀតត្រលប់វិញ ។ ថ្នាំបុរាណ ឬថ្នាំឫសឈើមួយចំនួន ក៏មានលាយសារធាតុសំណដែរ ។ ហាមឲ្យកូនអ្នកប្រើថ្នាំបំប៉នសុខភាព បើគ្រូពេទ្យមិនបានណែនាំទេនោះ ។

**ការពារគ្រួសាររបស់អ្នក ។**

- សូមឆែកមើលព័ត៌មានក្នុងវិបសៃត៍នេះ ៖ maine.gov/healthyhomes
- ហៅទូរស័ព្ទទៅលេខនេះ ដើម្បីសុំដំបូន្មាន ៖ **866-292-3474** • **អ្នកប្រើ TTY សូមហៅទៅលេខ ៖ លេខបន្តរបស់រដ្ឋមេន 711**